ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤៩ សហវ.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតអនុគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន

## គណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ៤៤ សសរចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន
- យោងលិខិតលេខ ៤៦៥ សជណ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់នៃការងារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef...@yahoo.com

## សម្រេច

**ប្រការ ១÷** ត្រូវបានបង្កើតអនុគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន ឬហៅកាត់ថា "អនុគណៈកម្មការដេញថ្លៃលក់ឈើ" ដែលមានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ស្វាយ ម៉េងគា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម | **ចាយ សាមិត្ត** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | អនុប្រធាន |
| ៣-ឯកឧត្តម | **អ៊ុង សំអាត** | អនុប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-លោកជំទាវ | **គីម សេដ្ឋានី** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥-ឯកឧត្តម | **សុន សុភ័ណ្ឌ** | នាយកខុទ្ទកាល័យ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៦-ឧត្តមសេនីយ៍ឯក | **ជុំ សទុឡា** | តំណាងឧត្តមសេនីយ៍ឯក **ហ៊ូ សាគុណ** | សមាជិក |
| ៧-ឧត្តមសេនីយ៍ត្រី | **អេង ហ៊ី** | តំណាងឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | សមាជិក |
| ៨-ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសាមីដែលពាក់ព័ន្ធ | | | សមាជិក |
| ៩-ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តសាមីដែលពាក់ព័ន្ធ | | | សមាជិក |
| ១០-ប្រធានមន្ទីរបរិស្ថាន ខេត្តសាមីដែលពាក់ព័ន្ធ | | | សមាជិក |
| ១១-នាយខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តសាមីដែលពាក់ព័ន្ធ | | | សមាជិក។ |

**ប្រការ ២÷** អនុគណៈកម្មការដេញថ្លៃលក់ឈើ មានភារកិច្ចជាសេនាធិការជូនគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន និងអនុវត្តផ្ទាល់ការងារបច្ចេកទេស និងនីតិវិធីដេញថ្លៃ ដូចខាងក្រោម÷

- រៀបចំសៀវភៅបន្ទុកដេញថ្លៃលក់ឈើ និងកូនឈើ
- រៀបចំលក់ឯកសារដេញថ្លៃ និងទទួលពាក្យសុំដេញថ្លៃ
- រៀបចំផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការដាក់ដេញថ្លៃលក់ឈើ និងកូនឈើ, ចាត់ចែងឲ្យមានការបង់ប្រាក់កក់ធានាការដេញថ្លៃ, បើកឯកសារដេញថ្លៃ, ពិនិត្យ និងវាយតម្លៃសំណុំឯកសារពាក្យសុំដេញថ្លៃ, និងធ្វើកំណត់ហេតុវាយតម្លៃសំណុំឯកសារដេញថ្លៃ
- រៀបចំប្រជុំដេញថ្លៃលក់ឈើ និងកូនឈើ ស្របតាមលក្ខខណ្ឌ នីតិវិធី ជាធរមាន និងតាមការសម្រេចរបស់គណៈកម្មការដេញថ្លៃលក់ឈើ
- ធ្វើរបាយការណ៍ ស្តីពីលទ្ធផលដេញថ្លៃលក់ឈើ និងកូនឈើ ជូនគណៈកម្មការដេញថ្លៃលក់ឈើ ពិនិត្យ សម្រេច និងប្រកាសលទ្ធផលដេញថ្លៃ ជាផ្លូវការ។

- រៀបចំសេចក្តីព្រាងកិច្ចសន្យា ដើម្បីគោរពស្នើសុំហត្ថលេខាឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មការដេញថ្លៃលក់ឈើ ជាមួយជ័យលាភី ដែលបានដេញថ្លៃឈ្នះ
- ចាត់ចែងឱ្យមានការដាក់ប្រាក់តម្កល់ធានាការអនុវត្តកិច្ចសន្យា ស្របតាមនីតិវិធី ជាធរមាន
- សម្របសម្រួលជាមួយស្ថាប័ន អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ និងក្នុងករណីចាំបាច់ លើកសំណើសុំអន្តរាគមន៍ពីឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន ដើម្បីសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការជម្រុញការអនុវត្តកិច្ចសន្យាលក់ឈើ និងកូនឈើ ជាមួយជ័យលាភី ឱ្យសម្រេចបានជោគជ័យ ដែលរួមមាន លិខិតអនុញ្ញាតដឹកជញ្ជូនឈើ និងកូនឈើ, លិខិតអនុញ្ញាតបង្កើតទីតាំងកែច្នៃឈើ និងលិខិតអនុញ្ញាតនានា ដែលពាក់ព័ន្ធ
- ត្រួតពិនិត្យ តាមដានការអនុវត្តសៀវភៅបន្ទុក និងកិច្ចសន្យាលក់ឈើ និងកូនឈើ និងការប្រមូលចំណូលពីការដេញថ្លៃលក់ឈើ និងកូនឈើ បង់ចូលថវិការដ្ឋ សម្រាប់ប្រើប្រាស់ក្នុងវិស័យអប់រំ
- ធ្វើរបាយការណ៍ជាប្រចាំ ជូនគណៈកម្មការដេញថ្លៃលក់ឈើ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការដេញថ្លៃលក់ឈើ ប្រគល់ជូន។

**ប្រការ ៣÷** អនុគណៈកម្មការនេះ មានលេខាធិការដ្ឋានមួយ ជាជំនួយការ។ លេខាធិការដ្ឋាននេះ មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១-ឯកឧត្តម **នេត មុន្នី** | អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃកសហវ | ប្រធាន |
| ២-លោក **មាស សុផល** | អគ្គនាយករង ក្រសួងបរិស្ថាន | អនុប្រធាន |
| ៣-ឯកឧត្តម **អ៊ុង សំអាត** | អនុប្រធានរដ្ឋបាលព្រៃឈើ នៃកសក | អនុប្រធាន |
| ៤-លោក **ហុង តារ៉ាវុធ** | ប្រធាននាយកដ្ឋាន នៃក្រសួងបរិស្ថាន | សមាជិក |
| ៥-លោក **វណ្ណា សំណាង** | អនុប្រធាននាយកដ្ឋាន នៃកសហវ | សមាជិក |
| ៦-លោក **សុខ ធី** | អនុប្រធាននាយកដ្ឋាន នៃកសហវ | សមាជិក |
| ៧-លោក **ហ៊ាន ម៉ុនណារិត** | អនុប្រធាននាយកដ្ឋាន នៃកសហវ | សមាជិក |
| ៨-លោក **ម៉េន លុច** | អនុប្រធាននាយកដ្ឋាននីតិកម្ម នៃកសហវ | សមាជិក |
| ៩-លោក **ណាំ ស៊ីនិត** | អនុប្រធាននាយកដ្ឋាន នៃកសហវ | សមាជិក |
| ១០-លោក **សុខា សោភ័ណ្ឌ** | អនុប្រធាននាយកដ្ឋាន នៃក្រសួងបរិស្ថាន | សមាជិក |
| ១១-លោក **សួន សុវណ្ណា** | អនុប្រធាននាយកដ្ឋាន រ.ព.ឈ នៃកសក | សមាជិក |
| ១២-លោកស្រី **សួន ពិនកាន្និកា** | ប្រធានការិយាល័យ នៃកសហវ | សមាជិក |
| ១៣-លោក **ខួន សុធី** | ប្រធានការិយាល័យ នៃកសក | សមាជិក |
| ១៤-លោក **អាន ពុទ្ធារ៉ា** | អនុប្រធានការិយាល័យ នៃក្រសួងបរិស្ថាន | សមាជិក |

១៥-លោកស្រី **ឆាន្ធ ម៉ិនសួលក្ខិណា** អនុប្រធានការិយាល័យ នៃកសក សមាជិក

១៦-លោក **ឈុំ សំណាង** មន្ត្រី រដ្ឋបាលព្រៃឈើ នៃកសក សមាជិក។

**ប្រការ ៤÷** លេខាធិការដ្ឋាន មានភារកិច្ចធ្វើជាជំនួយការជូនអនុគណៈកម្មការដេញថ្លៃលក់ឈើ លើការងាររដ្ឋបាលទូទៅ និងសម្របសម្រួលដល់ដំណើរការនីតិវិធីដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន ឱ្យប្រព្រឹត្តទៅបានដោយរលូន និងជោគជ័យ។

**ប្រការ ៥÷** គោលការណ៍មូលដ្ឋាន នីតិវិធី និងលក្ខខណ្ឌនៃសៀវភៅបន្ទុកដេញថ្លៃលក់ឈើ និងកូនឈើ, កិច្ចសន្យាលក់ឈើ និងកូនឈើ ត្រូវដាក់ឆ្លងកិច្ចប្រជុំគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន ពិនិត្យ ពិភាក្សា និងអនុម័ត។

**ប្រការ ៦÷** ក្នុងករណីប្រធានអនុគណៈកម្មការអវត្តមាន ប្រធានអនុគណៈកម្មការ ត្រូវចេញលិខិតជាលាយលក្ខអក្សរ ដើម្បីចាត់អនុប្រធាន០១រូប ដឹកនាំកិច្ចការជំនួស។

**ប្រការ ៧÷** គណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើដែល**

**គណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ